Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

ព័ត៌មានមួយចំនួនដែល មានប្រយោជន៍ សម្រាប់និយោជករបស់ពលករធ្វើការតាមផ្ទះ

តើអ្នកមានកាតព្វកិច្ចអ្វីខ្លះចំពោះពលករធ្វើការតាមផ្ទះដែលអ្នកជួល?

ថ្ងៃឈប់សម្រាក និងប្រាក់ឈ្នួល

តាមផ្លូវច្បាប់ក្នុងប្រទេសថៃ ពលករធ្វើការតាមផ្ទះទទួលបាននូវការឈប់សម្រាកដូចខាងក្រោមទោះបីជាពួកគេមានសញ្ជាតិអ្វីក៏ដោយ ៖

ថ្ងៃសម្រាកប្រចាំសប្តាហ៍៖ យ៉ាងហោចណាស់មួយថ្ងៃក្នុងមួយសប្តាហ៍

ថ្ងៃឈប់សម្រាកបុណ្យជាតិ៖ យ៉ាងហោចណាស់ ទទួលបានថ្ងៃសម្រាកបុណ្យជាតិដែលទទួលបានប្រាក់ឈ្នួល ចំនួន 13 ថ្ងៃក្នុងមួយឆ្នាំ

ការសុំច្បាប់ឈប់សម្រាកប្រចាំឆ្នាំ៖ យ៉ាងហោចណាស់ អាចសុំច្បាប់សម្រាកដែលទទួលបានប្រាក់ឈ្នួល ចំនួន 6 ថ្ងៃក្នុងមួយឆ្នាំសម្រាប់ពលករដែលធ្វើការបានរយៈពេល 12ខែ

ការសុំច្បាប់ឈប់សម្រាកឈឺ៖ ពលករ អាចសុំច្បាប់ឈប់សម្រាកឈឺដោយទទួលបានប្រាក់ឈ្នួលទៅតាមចំនួនថ្ងៃដែលពួកគាត់ឈឺ ជាអតិបរិមាចំនួន 30 ថ្ងៃ។ ពលករ ត្រូវបានអនុញ្ញាត អោយឈប់សម្រាករហូតដល់ពួកគាត់ជាសះស្បើយពីជំងឺ។

- ពលករធ្វើការតាមផ្ទះ មានសិទ្ធិទទួលបានប្រាក់ឈ្នួលមិនតិចជាងអត្រាប្រចាំថ្ងៃអប្បបរមាប្រកាសដោយគណៈកម្មាធិការជាតិប្រាក់ឈ្នួល ដែលអាត្រានេះខុសគ្នាទៅតាមខេត្តនីមួយៗ។ ឧទាហរណ៍ ប្រាក់ឈ្នួល អប្បបរមាដែលបានប្រកាសសម្រាប់ទីក្រុងបាងកកក្នុងឆ្នាំ 2024 គឺ 363 បាតក្នុងមួយថ្ងៃ។

របបថែទាំសុខភាពនិងសន្តិសុខសង្គម

ការចុះឈ្មោះដោយខ្លួនឯងដើម្បីទទួលបានរបបសន្តិសុខសង្គម៖
ពលករថៃធ្វើការតាមផ្ទះ អាចចុះឈ្មោះដោយខ្លួនឯងយោងតាមផ្នែកទី 40 នៃច្បាប់ស្តីពីសន្តិសុខសង្គម ដែលគ្របដណ្តប់លើពលកររក្រៅផ្លូវការ។ ជនជាតិថៃ ក៏មានសិទ្ធិទទួលបានគម្រោងធានារ៉ាប់រងសុខភាពជាសកលផងដែរ។.

ធានារ៉ាប់រងរបស់ក្រសួងសុខាភិបាលសាធារណៈសម្រាប់ពលកររទេសន្តរប្រវេសក៍ ៖
ពលកចំណាកស្រុកដែលធ្វើការតាមផ្ទះ ត្រូវទិញធានារ៉ាប់រងសុខភាពពីក្រសួងសុខាភិបាលសាធារណៈ (MOPH) ដើម្បីទទួលបានប័ណ្ណអនុញ្ញាតការងារ និងទទួលបានសេវាថែទាំសុខភាពក្នុងប្រទេសថៃ។ គម្រោងធានារ៉ាប់រងសម្រាប់ ពលកចំណាកស្រុករបស់ក្រសួងសុខាភិបាល ផ្តល់ជូនការធានារ៉ាប់រងសុខភាពដល់ពលកចំណាកស្រុកដែលមិនទទួលបានការធានារ៉ាប់រងក្រោមមូលនិធិសន្តិសុខសង្គមរហូតដល់ 2 ឆ្នាំសម្រាប់ការទិញធានារ៉ាប់រងម្តង ក្នុងតម្លៃ 3,200 បាតជាទូទៅ។

ត្រូវប្រាកដថាពលករធ្វើការតាមផ្ទះដែលអ្នកបានជួល មានទិដ្ឋាការដែលមានសុពលភាព មានលិខិតអនុញ្ញាតស្នាក់នៅ និងឯកសារអត្តសញ្ញាណកម្មផ្សេងៗទៀត។

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

បទប្បញ្ញត្តិថ្នាក់ក្រសួង លេខ 15 (ព.ស 2567) ស្តីពីការការពារពលកររ្វើការតាមផ្ទះ

បទប្បញ្ញត្តិនេះ ចូលជាធរមានចាប់ពីថ្ងៃទី 30 ខែមេសា ឆ្នាំ 2024 ក្រោមច្បាប់ការពារកម្លាំងពលកម្ម ព.ស 2541 អនុវត្តចំពោះនិយោជកដែលជួលពលកររ្វើការតាមផ្ទះ ដែលមិនបានចូលរួមក្នុងសកម្មភាពអាជីវកម្ម។

សេចក្តីសង្ខេបខ្លឹមសារសំខាន់ៗ៖

- ការស្នើសុំការធានាការងារឬការទទួលយកការធានាការងារពីពលករ ត្រូវបានហាមឃាត់។
- ហាមរើសអើងពលករដោយសារតែភេទ។
- ការបៀតបៀន ឬការគំរាមកំហែងផ្លូវភេទ ត្រូវបានហាមឃាត់។
- ត្រូវជូនដំណឹងពលករជាមុន មុនពេលបញ្ចប់កិច្ចសន្យារបស់ពួកគេ។
- ពលករ គួរតែធ្វើការ 8 ម៉ោងក្នុងមួយថ្ងៃ ដោយមានការសម្រាកយ៉ាងតិច 1 ម៉ោង។
- ពលករ ត្រូវមានថ្ងៃឈប់សម្រាក 1 ថ្ងៃក្នុងមួយសប្តាហ៍។
- មានថ្ងៃឈប់សម្រាកបុណ្យជាតិ ចំនួន 13 ថ្ងៃ ក្នុងមួយឆ្នាំ រួមទាំងទិវាពលកម្មផងដែរ។
- ពលករ មានសិទ្ធិសុំច្បាប់ឈប់សម្រាក ចំនួន 6 ថ្ងៃ ក្នុង១ឆ្នាំ។
- ច្បាប់ឈប់សម្រាកឈឺ ត្រូវបានអនុញ្ញាតតាមតម្រូវការ ដោយទទួលបានប្រាក់ឈ្នួលរហូតដល់ 30 ថ្ងៃក្នុងមួយឆ្នាំ។
- ពលករ អាចសុំច្បាប់ឈប់សម្រាកចាំបាច់ផ្ទាល់ខ្លួនបានរហូតដល់ 3 ថ្ងៃក្នុង១ឆ្នាំ។

ការបង់ប្រាក់ឈ្នួល ប្រាក់ឈ្នួលសម្រាប់ការធ្វើការថែមម៉ោង ប្រាក់ឈ្នួលសម្រាប់ថ្ងៃឈប់សម្រាក និងប្រាក់ឈ្នួលសម្រាប់ការធ្វើលើសម៉ោងនៅថ្ងៃឈប់សម្រាក

- ត្រូវធានាពលករបុរស និងស្ត្រីទទួលបានប្រាក់ឈ្នួលស្មើគ្នា។
- ត្រូវបើកប្រាក់ឈ្នួលជាលុយថៃ នៅកន្លែងបំពេញការងាររបស់ពលករ។
- ត្រូវផ្តល់ប្រាក់ឈ្នួលសម្រាប់ថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ សម្រាកបុណ្យប្រពៃណីជាតិ និងការសុំច្បាប់ឈប់សម្រាកប្រចាំឆ្នាំ។
- ត្រូវផ្តល់ប្រាក់បន្ថែម យ៉ាងតិច 1 ដងនៃប្រាក់ឈ្នួល ពីលើប្រាក់ឈ្នួលប្រចាំថ្ងៃសម្រាប់ការធ្វើការងារថ្ងៃឈប់សម្រាក។
- ត្រូវបង់ប្រាក់ឈ្នួលសម្រាប់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ដោយផ្អែកលើអត្រា ប្រាក់ឈ្នួលប្រចាំថ្ងៃ នៅ ពេលបញ្ឈប់ការងាពលករ។
- ត្រូវធានាថាប្រាក់ឈ្នួលមានភាពសុក្រឹត និងត្រូវបានទូទាត់ទាន់ពេល។
- មិនត្រូវកាត់ប្រាក់ឈ្នួល ប្រាក់ឈ្នួលសម្រាប់ការធ្វើការថែមម៉ោង ប្រាក់ឈ្នួលសម្រាប់ការធ្វើការថ្ងៃឈប់សម្រាក ឬប្រាក់ឈ្នួលសម្រាប់ការធ្វើការថែមម៉ោងនៅថ្ងៃឈប់សម្រាកទេ្បីយ។
- ត្រូវរក្សាប្រាក់ឈ្នួលត្រឹមកម្រិតប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ដោយច្បាប់ ឬលើសពីកម្រិតនោះ។
- ត្រូវអនុញ្ញាតឱ្យពលករមានសិទ្ធិដាក់ពាក្យបណ្តឹងជាមួយមន្ត្រីអធិការកិច្ចការងារ។

ការជួលពលការិនី

- ពលការិនីដែលមានផ្ទៃពោះ មិនត្រូវបានអនុញ្ញាតឱ្យធ្វើការពីម៉ោង 10:00 យប់ដល់ម៉ោង 6:00 ព្រឹក ហើយក៏មិនត្រូវបានអនុញ្ញាតឱ្យធ្វើការបន្ថែមម៉ោង ឬនៅថ្ងៃឈប់សម្រាកផងដែរ។
- ការឈប់សម្រាកលំហែមាតុភាពមានរយៈពេល 98 ថ្ងៃ ដោយទទួលបានប្រាក់ឈ្នួលរហូតដល់ 45 ថ្ងៃ។
- ការបញ្ឈប់ការងារដោយសារការមានផ្ទៃពោះ ត្រូវបានហាមឃាត់ជាកំហិត។

ពិន័យ

និយោជកដែលបំពាន ឬមិនគោរពតាមបទប្បញ្ញត្តិទាំងនេះ អាចប្រឈមនឹងការផាកពិន័យ ជាប់ពន្ធនាគារ ឬទាំងពីរ អាស្រ័យលើកាលៈទេសៈជាក់លាក់។

ប្រភព៖នាយកដ្ឋានការពារកម្លាំងពលកម្មនិងសុខុមាលភាព នៃក្រសួងការងារ